# **សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈ**

សូមផ្តល់សេចក្តីជូនដំណឹងដោយយោងតាមច្បាប់ M.G.L. c. 30A, **ក្រសួងការពារបរិស្ថាននៃរដ្ឋ MA** (MassDEP) កំពុងស្នើសុំធ្វើវិសោធនកម្ម **បទប្បញ្ញត្តិស្តីពីកម្មវិធីគ្រប់គ្រងធនធានទឹក** (310 CMR 36.00) ដែលបានដាក់ឲ្យប្រើប្រាស់ក្រោមច្បាប់ស្តីពីការគ្រប់គ្រងទឹកនៃរដ្ឋ Massachusetts (M.G.L. c . 21G)។ សំណើវិសោធនកម្មនឹងបន្ថែមលក្ខខណ្ឌនៃការចុះបញ្ជីលើការគ្រប់គ្រងទឹកដែលនឹងរឹតបន្តឹងលើការប្រើប្រាស់ទឹកដែលមិនសំខាន់នៅខាងក្រៅផ្ទះ ដោយអ្នកចុះបញ្ជីក្នុងអំឡុងពេលគ្រោះរាំងស្ងួតដែលប្រកាសដោយរដ្ឋមន្ត្រីក្រសួងថាមពល និងកិច្ចការបរិស្ថាន។ ប្រការនេះនឹងជួយសម្រួលការប្រើប្រាស់ទឹកក្នុងអំឡុងពេលគ្រោះរាំងស្ងួតតាមរយៈផែនការគ្រប់គ្រងគ្រោះរាំងស្ងួតរបស់រដ្ឋ Massachusetts ដូចដែលបានធ្វើបច្ចុប្បន្នភាពក្នុងឆ្នាំ 2019 ហើយ នឹងជួយធានាឱ្យមានទឹកគ្រប់គ្រាន់ដើម្បីសុខភាពសាធារណៈ សុវត្ថិភាពសាធារណៈ និងស្ថិរភាពសេដ្ឋកិច្ចនៅពេលដែលការផ្គត់ផ្គង់ទឹកត្រូវបានជួបវិបត្តិដោយសារគ្រោះរាំងស្ងួត និងជួយធានាឱ្យមានតុល្យភាពនៃការប្រើប្រាស់ទឹក និងការការពារធនធានធម្មជាតិ។

## **<u>មតិ និងសវនាការសាធារណៈ</u>**

MassDEP នឹងធ្វើសវនាការសាធារណៈតាមអនឡាញចំនួនពីរលើក។
**ថ្ងៃព្រហស្បតិ៍ ទី 27 ខែតុលា ឆ្នាំ 2022 ម៉ោង 5:30 ល្ងាច។** ចុះឈ្មោះជាមុននៅ៖
https://us06web.zoom.us/meeting/register/tZEkf-yupz4jGN0yBZqAV6UE95BYiF4QgDpT
**ថ្ងៃសុក្រ ទី 28 ខែតុលា ឆ្នាំ 2022 វេលាម៉ោង 10:00 ព្រឹក។** ចុះឈ្មោះជាមុននៅ៖
https://us06web.zoom.us/meeting/register/tZcpdOGsqzIpGtDBSqOCdhU_8gy9ShmaYa0v

បន្ទាប់ពីចុះឈ្មោះហើយ អ្នកនឹងទទួលបានអ៊ីមែលបញ្ជាក់ដែលមានព័ត៌មានអំពីការចូលរួមក្នុងកិច្ចប្រជុំ។ មតិអំពីសំណើសុំការកែប្រែអាចត្រូវបានបង្ហាញដោយផ្ទាល់មាត់នៅក្នុងសវនាការសាធារណៈ។

**រាល់មតិជាលាយលក្ខណ៍អក្សរនឹងត្រូវបានទទួលយករហូតដល់ម៉ោង 5:00 ល្ងាច នៅថ្ងៃចន្ទ ទី 7 ខែវិច្ឆិកា ឆ្នាំ 2022**។ រាល់មតិដែលបានដាក់ស្នើត្រូវតែបញ្ចូលឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់អ្នកដែលផ្តល់មតិ។ សូមផ្ញើមតិតាមអ៊ីមែលទៅ dep.talks@mass.gov ហើយសរសេរបញ្ចូល *បទប្បញ្ញត្តិ WMA* នៅក្នុងបន្ទាត់ប្រធានបទ។ ជំនួសឱ្យការផ្ញើតាមប្រព័ន្ធអេឡិចត្រូនិក សូមផ្ញើច្បាប់ចម្លងក្រដាសមួយច្បាប់ទៅកាន់ការិយាល័យការពារធនធាននៅក្រសួងការពារបរិស្ថាននៃរដ្ឋ Massachusetts - កម្មវិធីគ្រប់គ្រងទឹក, One Winter Street, 5th floor, Boston, MA  02108 ជូន៖ បទប្បញ្ញត្តិ WMA

សំណើបទប្បញ្ញត្តិមាននៅ៖ www.mass.gov/eea/agencies/massdep/news/comment/។  សំណើបទប្បញ្ញត្តិ និងរាល់មតិទាំងអស់ដែលបានដាក់ពីមុននៅក្នុងខែកក្កដា ឆ្នាំ 2021 មាននៅ 310 CMR 36.00 ៖ កម្មវិធីគ្រប់គ្រងធនធានទឹករដ្ឋ Massachusetts | Mass.gov។
មតិដែលបានដាក់ស្នើក្នុងឆ្នាំ 2021 គឺមាននៅក្នុងឯកសារ ហើយមិនចាំបាច់ដាក់ស្នើឡើងវិញទេ។

សម្រាប់កិច្ចសម្របសម្រួលពិសេសសម្រាប់សវនាការនេះ សូមទូរសព្ទទៅការិយាល័យចម្រុះ MassDEP តាមរយៈលេខ 617-292-5751។  TTY# សេវាកម្ម MassRelay តាមលេខ 1-800-439-2370។  ព័ត៌មាននេះមានជាទម្រង់ផ្សេងៗតាមតម្រូវការ។

តាមបញ្ជារបស់ក្រសួង

Martin Suuberg, ស្នងការ